អាជ្ញាបណ្ណ និងការត្រួតពិនិត្យ
របស់ភ្នាក់ងារដែលមានសមត្ថកិច្ចសម្រាប់អាជីវកម្មលក់ដុំ
លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម

ដ្យាក្រាមសម្រាប់ការស្នើរសុំអាជ្ញាបណ្ណ និងការត្រួតពិនិត្យសម្រាប់អាជីវកម្ម លក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម

អាជ្ញាបណ្ណ និងវិញ្ញាបនប័ត្រសំខាន់ៗចំនួន៤

ខ្ញុំចង់បើកអាជីវកម្ម លក់ដុំ លក់រាយ លើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្មថ្មីមួយ

អាជ្ញាបណ្ណ និងវិញ្ញាបនប័ត្រសំខាន់ៗ

- មុនដំណើរការអាជីវកម្ម-

1 **ក្រសួងពាណិជ្ជកម្ម**

វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

2 **អគ្គនាយកដ្ឋានពន្ធដារ**

ការចុះបញ្ជីពន្ធដារ អាករបន្ថែម បណ្ណពន្ធប៉ាតង់ និងពន្ធប្រថាប់ត្រា

3 **ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

អាជ្ញាបណ្ណអាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម

4 **សាលារាជធានីភ្នំពេញ**

លិខិតអនុញ្ញាត(បើកទីតាំងអាជីវកម្ម)

អាជ្ញាបណ្ណ និងវិញ្ញាបនប័ត្រ ផ្សេងៗ

- ពេលដំណើរការអាជីវកម្ម -

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ចុះបញ្ជិការប្រកាសបើកសហគ្រាស ចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន ចុះបញ្ជិកាសៀវភៅបើកប្រាក់ ចុះទិដ្ឋាកាបទបញ្ជាផ្ទៃក្នុង (ត្រូវជូនដំណឹងដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីការចាប់ដំណើរការ និងជួលបុគ្គលិក ក្នុងកំឡុងពេល៣០ថ្ងៃ)

អគ្គនាយកដ្ឋានពន្ធដារ

ពន្ធលើស្លាកយីហោ

សាលារាជធានីភ្នំពេញ

លិខិតអនុញ្ញាតស្លាកយីហោ

ការត្រួតពិនិត្យពេលដំណើរការស្នើសុំ

ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ការត្រួតពិនិត្យដោយមន្រ្តីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សាលារាជធានីភ្នំពេញ

ការត្រួតពិនិត្យទីតាំង

ការត្រួតពិនិត្យពេលដំណើរការអាជីវកម្ម

ក្រសួងមហាផ្ទៃ

ការត្រួតពិនិត្យសន្តិសុខ និងសុវត្ថិភាពអគ្គីភ័យ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ការត្រួតពិនិត្យតាមច្បាប់ការងារ

សាលារាជធានីភ្នំពេញ

ការត្រួតពិនិត្យទីតាំង

ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ការត្រួតពិនិត្យដោយមន្រ្តីក្រសួង

ដំណាក់កាលសំខាន់ៗក្នុងការស្នើសុំអាជ្ញាបណ្ណសម្រាប់អាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្មនីមួយៗ

ដំណាក់កាលក្នុងការស្នើសុំអាជ្ញាបណ្ណសម្រាប់អាជីវកម្មលក់ដុំ លក់រាយលើ ការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម (មិនជាប់ពាក់ព័ន្ធសកម្មភាពនាំចេញ នាំចូល)

បួនដំណាក់កាល- រយៈពេល១៥ថ្ងៃ - ៣០ថ្ងៃ

ខ្ញុំចង់ស្នើរសុំអាជ្ញាបណ្ណសម្រាប់អាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម (មិនជាប់ពាក់ព័ន្ធសកម្មភាពនាំចេញ នាំចូល)

ដំណាក់កាល១

លោក អ្នកអាចធ្វើការស្នើសុំតាមរយៈ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាខេត្ត ក្រុង

ដំណាក់កាល២

រៀបចំឯកសារដូចមានក្នុងឧបសម្ព័ន្ធ១១

ដំណាក់កាល៣

បង់កម្រៃដូចមានបង្ហាញក្នុងឧបសម្ព័ន្ធ១១

ដំណាក់កាល៤

ទទួលបានអាជ្ញាបណ្ណសម្រាប់អាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម

បណ្ណព័ត៌មានសំខាន់ៗសម្រាប់អាជីវកម្មលក់ដុំ លិកិរាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម

ការស្នើសុំអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រសម្រាប់ អាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើម កសិកម្ម

តើត្រូវមានអាជ្ញាបណ្ណឬវិញ្ញាបនប័ត្រអ្វីខ្លះសម្រាប់ដំណើការអាជីវកម្មលក់ដុំ លក់រាយ លើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម

គ្រប់អាជីវកម្មដែលលក់ដុំ លក់រាយ លើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម ដូចជា ថ្នាំសត្វល្អិត ជីគីមី គ្រាប់ពូជ ចំណីសត្វ និងឱសថសម្រាប់ព្យាបាលសត្វ ក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវមានអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រមួយចំនួនដូចខាងក្រោមសម្រាប់ដំណើរការៈ

- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- អាជ្ញាបណ្ណអាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម
- ការចុះបញ្ជីពន្ធដារ ពន្ធប៉ាតង់ អាករលើតម្លៃបន្ថែម និងពន្ធប្រថាប់ត្រា
- លិខិតអនុញ្ញាត(បើកទីតាំងអាជីវកម្ម)
- ចុះបញ្ជិការប្រកាសបើកសហគ្រាស សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន សៀវភៅបើកប្រាក់ ចុះទិដ្ឋាកាបទបញ្ជាផ្ទៃក្នុង(ក្នុងកំឡុងពេល៣០ថ្ងៃ)។
- ពន្ធលើស្លាកយីហោ
- លិខិតអនុញ្ញាតស្លាកយីហោ

A joint initiative by

តើលោកអ្នកអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រនៅឯណា?

គ្រប់អាជីវកម្មដែលលក់ដុំ លក់រាយ លើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្មក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវ អាជ្ញាបណ្ណអាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម និងអាជ្ញាបណ្ណឬវិញ្ញាបនប័ត្រជាប់ទាក់ទងមួយចំនួនទៀត។ លោកអ្នកអាចធ្វើការស្នើសុំអាជ្ញាបណ្ណឬវិញ្ញាបនប័ត្រទាំងនោះនៅៈ

- ចំពោះអាជ្ញាបណ្ណអាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម លោក អ្នកអាចធ្វើការសុំចុះអាជ្ញាបណ្ណនេះតាមរយៈក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅភ្នំពេញ ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទភ្នំពេញ ខេត្តនានា
- ចំពោះវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លោក អ្នកអាចធ្វើការសុំចុះវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម តាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្ម www.businessregistration.moc.gov.kh ឬលោកអ្នកអាចអញ្ជើញទៅកាន់ នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មខេត្តក្រុង ដើម្បីជួយ និងផ្តល់ជាព័ត៌មានសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មរបស់លោក អ្នក។
- ចំពោះការចុះបញ្ជីពន្ធដារ ពន្ធប៉ាតង់ អាករលើតម្លៃបន្ថែម និងពន្ធប្រថាប់ត្រា លោក អ្នកអាចធ្វើការសុំចុះបញ្ជី នៅអគ្គនាយកដ្ឋានពន្ធដារ(សាលាជាតិពន្ធដារ) ឬការិយាល័យពន្ធដារ ស្រុក ខណ្ឌ
- ចំពោះលិខិតអនុញ្ញាត(បើកទីតាំងអាជីវកម្ម) លោកអ្នកអាចអញ្ជើញទៅកាន់សាលារាជធានី ខេត្តក្រុងដែលអាជីវកម្មលោកអ្នកស្ថិតនៅ
- ចំពោះ ចុះបញ្ជិការប្រកាសបើកសហគ្រាស សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន សៀវភៅបើកប្រាក់ ចុះទិដ្ឋាកាបទបញ្ជាផ្ទៃក្នុង លោក អ្នកអាចអញ្ជើញទៅកាន់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(តាមរយៈប្រព័ន្ធonlineទទួលស្គាល់ដោយក្រសួងការងារ)។
- ចំពោះពន្ធលើស្លាកយីហោ លោក អ្នកអាចធ្វើការសុំចុះបញ្ជីបាន នៅអគ្គនាយកដ្ឋានពន្ធដារ ឬការិយាល័យពន្ធដារ ស្រុក ខណ្ឌ
- ចំពោះលិខិតអនុញ្ញាតស្លាកយីហោ លោក អ្នកអាចអញ្ជើញទៅកាន់សាលារាជធានី ខេត្ត ក្រុង ដែលអាជីវកម្មលោកអ្នកស្ថិតនៅ

តើលោកអ្នកត្រូវមានសំណុំឯកសារអ្វីខ្លះដើម្បីស្នើសុំអាជ្ញាបណ្ណអាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម?

លោកអ្នកតម្រូវឱ្យមានសំណុំឯកសារមួយចំនួន ដូចខាងក្រោមសម្រាប់ដំណើរការស្នើសុំៈ

- បំពេញពាក្យសុំដែលមានត្រា

- ប្រវត្តិរូបសង្ខេបនៃម្ចាស់អាជីវកម្មភ្ជាប់ជាមួយរូបថត ៤X៦ ដែលមានការបញ្ជាក់ដោយអាជ្ញាធរមូលដ្ឋាន
- អត្តសញ្ញាណប័ណ្ណថតចម្លងចំនួន២ច្បាប់
- កិច្ចសន្យាអាជីវកម្ម
- លិខិតអនុញ្ញាតចំពោះទីតាំងស្តុក ចេញដោយក្រសួងមន្ទីរបរិដ្ឋាន (ចំពោះតែថ្នាំសំលាប់សត្វល្អិតតែប៉ុណ្ណោះ)

តើអាជ្ញាបណ្ណអាជីវកម្មនេះ ផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់អាជីវកម្មលោកអ្នក?

អាជ្ញាបណ្ណអាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្មនេះផ្តល់អត្ថប្រយោជន៍ដូចខាងក្រោម៖

1. អាជីវកម្មលោកអ្នកត្រូវគេទទួលស្គាល់ថាជានិតិបុគ្គល និងទទួលបានការការពារដោយច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា
2. ផ្តល់ទំនុកចិត្តដល់ដៃគូអាជីវកម្ម ដែលមានសារៈសំខាន់សម្រាប់ឧត្តមភាព និងកាលានុវត្តភាពក្នុងអាជីវកម្ម ព្រមទាំងជម្រុញឱ្យទទួលបានធនធានសម្រាប់អាជីវកម្ម ដូចជាហិរញ្ញប្បទានជាដើម
3. លោកអ្នកទទួលបានការប្រឹក្សាជាមន្ត្រីជំនាញលើការចាប់ផ្តើមអាជីវកម្ម ដំណើរការអាជីវកម្ម និងការការពារអតិថិជន

តើការត្រួតពិនិត្យអ្វីខ្លះដែលនឹងកើតមានសម្រាប់អាជីវកម្មនេះ?

កំឡុងពេលស្នើសុំអាជ្ញាបណ្ណអាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម លោកអ្នកត្រូវទទួលរងការត្រួតពិនិត្យ (១)ការត្រួតពិនិត្យដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទភ្នំពេញ ខេត្តនានា (២)ត្រួតពិនិត្យទីតាំងដោយអាជ្ញាធរមូលដ្ឋាន ដោយក្រសួងមហាផ្ទៃ

នៅពេលដែលលោកអ្នក ដំណើការអាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម លោកអ្នកត្រូវទទួលរងការត្រួតពិនិត្យ (១)ប្រព័ន្ធគ្រប់គ្រងអគ្គីភ័យ និងប្រព័ន្ធការពារ សន្តិសុខ សុវត្ថិភាពដោយក្រសួងមហាផ្ទៃ (២)អធិការកិច្ចការងារដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (៣) ត្រួតពិនិត្យដោយអាជ្ញាធរមូលដ្ឋាន ដោយក្រសួងមហាផ្ទៃ (៤)ត្រួតពិនិត្យដោយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទភ្នំពេញ ខេត្តនានា។

ម៉ាទ្រីកនៃព័ត៌មានសម្រាប់អាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម

បញ្ជីនៃអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ លិខិតអនុញ្ញាតសម្រាប់អាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម (មិនជាប់ពាក់ព័ន្ធសកម្មភាពនាំចេញ នាំចូល)

ដំណាក់កាល	ប្រភេទអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	ស្ថាប័នមានសមត្ថកិច្ចក្នុងការចេញ អាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	សុពលភាព	កម្មវត្ថុរបស់អាជ្ញាបណ្ណឬវិញ្ញាបនប័ត្រ	តើខ្ញុំអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រនៅឯណា?	តើខ្ញុំត្រូវមានសំណុំឯកសារអ្វីខ្លះដើម្បីអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវរង់ចាំរយៈពេលប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវចំណាយប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	កម្រងឯកសារ គតិយុត្តិយោង

ដំណាក់កាល ១	វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម	ក្រសួងពាណិជ្ជកម្ម	៩៩ឆ្នាំ	ផ្តល់នូវភាពស្របច្បាប់ដល់ក្រុមហ៊ុនសហគ្រាសពាណិជ្ជតាមរយៈការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម	លោក អ្នកអាចធ្វើការសុំចុះវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម www.businessregistration.moc.gov.kh ឬលោក អ្នកអាចអញ្ជើញទៅកាន់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មខេត្តក្រុង ដើម្បីជួយ និងផ្តល់ជាព័ត៌មានសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មរបស់លោក អ្នក។	លោក អ្នកតម្រូវឱ្យមានសំណុំឯកសារមួយចំនួនដូចខាងក្រោមសម្រាប់ដំណើរការសុំចុះវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ៖
						- ឯកសារបញ្ជាក់អាសយដ្ឋានដែលអាចជា វិក័យបត្រអគ្គិសនី វិក័យបត្រទឹក ឬកិច្ចសន្យាជួលផ្ទះឬអគារ លិខិតប្រៃសណីយ៍ជាដើម
						- លក្ខន្តិកៈក្រុមហ៊ុន
						- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ម្ចាស់ហ៊ុន និងអភិបាល
						- រូបថត ៤ x ៦
						- សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អភិបាល ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
						- ក្នុងករណីម្ចាស់ហ៊ុនជានីតិបុគ្គល៖
						  ○ ច្បាប់ចម្លងឯកសារគតិយុត្តិនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ស្របតាមការតម្រូវរបស់បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
						  ○ សេចក្តីសម្រេចក្នុងការបង្កើតក្រុមហ៊ុន និងការតែងតាំងអ្នកតំណាងនីតិបុគ្គលជាម្ចាស់ហ៊ុន
						- ក្នុងកំឡុងពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ក្រុមហ៊ុនត្រូវផ្ញើមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនូវឯកសារដូចខាងក្រោម៖
						  ○ លក្ខន្តិកៈច្បាប់ដើមចំនួន០២ច្បាប់
						  ○ ករណីម្ចាស់ហ៊ុនជានីតិបុគ្គល៖
						    ▪ សេចក្តីសម្រេចក្នុងការបង្កើតក្រុមហ៊ុន និងតែងតាំងអ្នកតំណាងនីតិបុគ្គលម្ចាស់ហ៊ុន ច្បាប់ដើមចំនួន០១ច្បាប់
						    ▪ លិខិតច្បាប់ដើមបញ្ជាក់អំពីឈ្មោះគណនីរបស់ក្រុមហ៊ុនដែលបានបើកនៅធនាគារណាមួយចំនួន០១ច្បាប់
						- ក្នុងករណី នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មមិនបានទទួលលក្ខន្តិកៈច្បាប់ដើមក្នុងថិរវេលា៣០ថ្ងៃនេះទេ ក្រសួងពាណិជ្ជកម្មអាចជំទាស់នឹងការចុះបញ្ជី និងលុបចោលការចុះបញ្ជីពាណិជ្ជកម្ម។
							ដើម្បីទទួលបានវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មត្រូវការរយៈពេលពី០៣ថ្ងៃ ទៅ០៥ថ្ងៃបន្ទាប់ពីបានបំពេញសំណុំឯកសារត្រឹមត្រូវនិងគ្រប់គ្រាន់តាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម។	កម្រៃសេវាសម្រាប់ការសុំវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មគឺមានចំនួន ១.៦៨០.០០០ រៀល	- ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
									- ច្បាប់ស្តីពីវិសោធនកម្មស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
									- ប្រកាសលេខ២១៣៧ ណ ចបព ប្រក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៦
									- ប្រកាសលេខ២៩៩៧ ណ ចបព ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៥
									- ប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៤
									- តារាងឧបសម្ព័ន្ធ១ភ្ជាប់នឹងប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៤

	វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម	ក្រសួងពាណិជ្ជកម្ម	៩៩ឆ្នាំ	***ប្រសិនបើលោកអ្នកចុះបញ្ជីជាសាខា ឬការិយាល័យតំណាង***	លោក អ្នកអាចធ្វើការសុំចុះវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម www.businessregistration.moc.gov.kh ឬលោក អ្នកអាចអញ្ជើញទៅកាន់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មខេត្តក្រុង ដើម្បីជួយ និងផ្តល់ជាព័ត៌មានសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មរបស់លោក អ្នក។	លោក អ្នកតម្រូវឱ្យមានសំណុំឯកសារមួយចំនួនដូចខាងក្រោមសម្រាប់ដំណើរការសុំចុះវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ៖ - ឯកសារបញ្ជាក់អាសយដ្ឋានដែលអាចជា វិក័យបត្រអគ្គិសនី វិក័យបត្រទឹក ឬកិច្ចសន្យាជួលផ្ទះឬអគារ លិខិតប្រៃណីយ៍ជាដើម - ច្បាប់ចម្លងឯកសារគតិយុត្តិនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ដែលទទួលស្គាល់ដោយច្បាប់ - សេចក្តីសម្រេចរបស់ក្រុមហ៊ុនដើមបង្កើតសាខា ឬការិយាល័យតំណាង និងតែងតាំងអភិបាលសាខាឬការិយាល័យតំណាង - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ នាយកការិយាល័យតំណាង ឬសាខា - រូបថត ៤ x ៦	ដើម្បីទទួលបានវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មត្រូវការរយៈពេលពី០៣ថ្ងៃ ទៅ០៥ថ្ងៃបន្ទាប់ពីបានបំពេញសំណុំឯកសារត្រឹមត្រូវនិងគ្រប់គ្រាន់តាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម។	កម្រៃសេវាសម្រាប់ការសុំវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មគឺមានចំនួន ១.៦៨០.០០០ រៀល	- ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម - ច្បាប់ស្តីពីវិសោធនកម្មស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម - ប្រកាសលេខ២១៣៧ ណ ចបព ប្រក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៦ - ប្រកាសលេខ២៩៩៧ ណ ចបព ប្រក ចុះថ្ងៃ

ដំណាក់កាល	ប្រភេទអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	ស្ថាប័នមានសមត្ថកិច្ចក្នុងការចេញអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	សុពលភាព	កម្មវត្ថុរបស់អាជ្ញាបណ្ណឬវិញ្ញាបនប័ត្រ	តើខ្ញុំអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រនៅឯណា?	តើខ្ញុំត្រូវមានសំណុំឯកសារអ្វីខ្លះដើម្បីអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវរង់ចាំរយៈពេលប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវចំណាយប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	កម្រងឯកសារគតិយុត្តិយោង
						- សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់នាយកការិយាល័យតំណាង ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា			ទី ២៩ ខែធ្នូ ឆ្នាំ ២០១៥ - ប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៤ - តារាងឧបសម្ព័ន្ធ១ភ្ជាប់នឹងប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៤

	វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម	ក្រសួងពាណិជ្ជកម្ម	៩៩ឆ្នាំ	***ប្រសិនបើលោកអ្នកចុះបញ្ជីជាក្រុមហ៊ុនសហកម្មសិទ្ធិ***	លោក អ្នកអាចធ្វើការសុំចុះវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម www.businessregistration.moc.gov.kh ឬលោក អ្នកអាចអញ្ជើញទៅកាន់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មខេត្តក្រុង ដើម្បីជួយ និងផ្តល់ជាព័ត៌មានសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មរបស់លោក អ្នក។	លោក អ្នកតម្រូវឱ្យមានសំណុំឯកសារមួយចំនួនដូចខាងក្រោមសម្រាប់ដំណើរការសុំចុះវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ៖
						- ឯកសារបញ្ជាក់អាសយដ្ឋានដែលអាចជា វិក័យបត្រអគ្គិសនី វិក័យបត្រទឹក ឬ កិច្ចសន្យាជួលផ្ទះឬអគារ លិខិតប្រៃសណីយ៍ជាដើម
						- កិច្ចសន្យាបង្កើតក្រុមហ៊ុន
						- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ម្ចាស់ហ៊ុន និងអភិបាល
						- រូបថត ៤ x ៦
						- សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អភិបាល ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
						- ក្នុងករណីសហកម្មសិទ្ធិករជានីតិបុគ្គល:
						  ○ ច្បាប់ចម្លងឯកសារគតិយុត្តិនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ស្របតាមការតម្រូវរបស់បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
						  ○ សេចក្តីសម្រេចក្នុងការបង្កើតក្រុមហ៊ុន និងការតែងតាំងអ្នកតំណាងនីតិបុគ្គលជាសហកម្មសិទ្ធិករ
						- ក្នុងកំឡុងពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ក្រុមហ៊ុនត្រូវផ្ញើមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនូវឯកសារដូចខាងក្រោម៖
						  ○ កិច្ចសន្យាបង្កើតក្រុមហ៊ុនច្បាប់ដើមចំនួន០២ច្បាប់
						  ○ ករណីសហកម្មសិទ្ធិករជានីតិបុគ្គល៖
						    ▪ សេចក្តីសម្រេចក្នុងការបង្កើតក្រុមហ៊ុន និងតែងតាំងអ្នកតំណាងនីតិបុគ្គលជាសហកម្មសិទ្ធិករច្បាប់ដើមចំនួន០១ច្បាប់
						- ក្នុងករណី នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មមិនបានទទួលលក្ខន្តិកៈច្បាប់ដើមក្នុងចិរវេលា៣០ថ្ងៃនេះទេ ក្រសួងពាណិជ្ជកម្មអាចជំទាស់នឹងការចុះបញ្ជី និងលុបចោលការចុះបញ្ជីពាណិជ្ជកម្ម។
							ដើម្បីទទួលបានវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មត្រូវការរយៈពេលពី០៣ថ្ងៃ ទៅ០៥ថ្ងៃ បន្ទាប់ពីបានបំពេញសំណុំឯកសារត្រឹមត្រូវនិងគ្រប់គ្រាន់តាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម។	កម្រៃសេវាសម្រាប់ការសុំវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មគឺមានចំនួន ១.៦៨០.០០០ រៀល	- ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
									- ច្បាប់ស្តីពីវិសោធនកម្មស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
									- ប្រកាសលេខ២១៣ពណ ចបព ប្រក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៦
									- ប្រកាសលេខ២៩៩ពណ ចបព ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៥
									- ប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៤
									- តារាងឧបសម្ព័ន្ធ១ភ្ជាប់នឹងប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៤

	វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម	ក្រសួងពាណិជ្ជកម្ម	៩៩ឆ្នាំ	***ប្រសិនបើលោកអ្នកចុះបញ្ជីជាសហគ្រាសឯកបុគ្គល***	លោក អ្នកអាចធ្វើការសុំចុះវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម www.businessregistration.moc.gov.kh ឬលោក អ្នកអាចអញ្ជើញទៅកាន់	លោក អ្នកតម្រូវឱ្យមានសំណុំឯកសារមួយចំនួនដូចខាងក្រោមសម្រាប់ដំណើរការសុំចុះវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ៖ - ឯកសារបញ្ជាក់អាសយដ្ឋានដែលអាចជា វិក័យបត្រអគ្គិសនី វិក័យបត្រទឹក ឬ កិច្ចសន្យាជួលផ្ទះឬអគារ លិខិតប្រៃសណីយ៍ជាដើម - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ឯកកម្មសិទ្ធិករ	ដើម្បីទទួលបានវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មត្រូវការរយៈពេល ពី០៣ ទៅ០៥ថ្ងៃ បន្ទាប់ពីបានបំពេញសំណុំឯកសារត្រឹមត្រូវនិងគ្រប់គ្រាន់តាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជី	កម្រៃសេវាសម្រាប់ការសុំវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ឯកកម្មសិទ្ធិ) គឺមានចំនួន ៣០០. ០០០ រៀល	- ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម - ច្បាប់ស្តីពីវិសោធនកម្មស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

ដំណាក់កាល	ប្រភេទអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	ស្ថាប័នមានសមត្ថកិច្ចក្នុងការចេញអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	សុពលភាព	កម្មវត្ថុរបស់អាជ្ញាបណ្ណឬវិញ្ញាបនប័ត្រ	តើខ្ញុំអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រនៅឯណា?	តើខ្ញុំត្រូវមានសំណុំឯកសារអ្វីខ្លះដើម្បីអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវរង់ចាំរយៈពេលប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវចំណាយប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	កម្រងឯកសារគតិយុត្តិយោង
					នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មខេត្តក្រុង ដើម្បីជួយ និងផ្តល់ជាព័ត៌មានសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មរបស់លោក អ្នក។	- រូបថត ៤ x ៦របស់ឯកកម្មសិទ្ធិករ - សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់ឯកកម្មសិទ្ធិករថា ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។	ពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម។		- ប្រកាសលេខ២១៣៣ណ ចបព ប្រក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៦ - ប្រកាសលេខ២៩៩៣ណ ចបព ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៥ - ប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៤ - តារាងឧបសម្ព័ន្ធ១ភ្ជាប់នឹងប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៤
ដំណាក់កាល ២	លិខិតអនុញ្ញាតអាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម	ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	៣ឆ្នាំ	ទទួលបានភាពស្របច្បាប់សម្រាប់អាជីវកម្មលោកអ្នកជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	លោក អ្នកអាចធ្វើការសុំចុះ លិខិតអនុញ្ញាតអាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្មនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬ សាកសួរព័ត៌មាននៅ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	លោក អ្នកតម្រូវឱ្យមានសំណុំឯកសារមួយចំនួនដូចខាងក្រោមសម្រាប់ដំណើរការសុំលិខិតអនុញ្ញាតអាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម - បំពេញពាក្យសុំដែលមានត្រា - ប្រវត្តិរូបសង្ខេបនៃម្ចាស់អាជីវកម្មភ្ជាប់ជាមួយរូបថត៤X៦ ដែលមានការបញ្ជាក់ដោយអាជ្ញាធរមូលដ្ឋាន - អត្តសញ្ញាណប័ណ្ណថតចម្លងចំនួន២ច្បាប់ - កិច្ចសន្យាអាជីវកម្ម - លិខិតអនុញ្ញាតចំពោះទីតាំងស្តុក ចេញដោយក្រសួង មន្ទីរបរិដ្ឋាន (ចំពោះតែថ្នាំសំលាប់សត្វល្អិតតែប៉ុណ្ណោះ)	ដើម្បីទទួលបានលិខិតអនុញ្ញាតអាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្មបន្ទាប់ពីបានបំពេញសំណុំឯកសារត្រឹមត្រូវនិងគ្រប់គ្រាន់ (ចេញដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ត្រូវការរយៈពេល៖ - ១៥ថ្ងៃ ចំពោះដីក្រោម ៥០តោន - ៣០ថ្ងៃ ចំពោះដីលើសពី៥០តោន - ១៥ថ្ងៃចំពោះថ្នាំកសិកម្មក្រោម១តោន - ៣០ថ្ងៃចំពោះថ្នាំកសិកម្មលើសពី១តោន	កម្រៃសេវាសម្រាប់ការសុំលិខិតអនុញ្ញាតអាជីវកម្មលក់ដុំ លក់រាយលើការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្មដូចខាងក្រោម៖ - ៥០.០០០រៀល ចំពោះដីក្រោម ៥០តោន - ១០០.០០០រៀល ចំពោះដីលើសពី៥០តោន-១០០តោន - ១៥០.០០០រៀល ចំពោះដីលើសពី១០០តោន-៥០០តោន - ២០០.០០០រៀល ចំពោះដីលើសពី៥០០តោន-១.០០០តោន - ៤០០.០០០រៀល ចំពោះដីលើសពី១.០០០តោន-២.០០០តោន - ត្រូវយកកម្រៃមូលដ្ឋានសម្រាប់បរិមាណ២០០០តោនបូកបន្ថែមកម្រៃតាមបរិមាណដូចមានចែងខាងលើ ចំពោះដីលើសពី២.០០០តោន - ៥០.០០០រៀល ចំពោះថ្នាំកសិកម្មក្រោម១តោន - ១០០.០០០រៀល ចំពោះថ្នាំកសិកម្មលើសពី១តោន-៥តោន - ១៥០.០០០រៀល ចំពោះថ្នាំកសិកម្មលើសពី៥តោន-១០តោន - ២០០.០០០រៀល ចំពោះថ្នាំកសិកម្មលើសពី១០តោន-២០តោន	- ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម - ប្រកាសរួមលេខ ១០១៣ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១២ - ប្រកាសលេខ ៤១៥ ប្រក.សកសចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១២

ដំណាក់កាល	ប្រភេទអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	ស្ថាប័នមានសមត្ថកិច្ចក្នុងការចេញអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	សុពលភាព	កម្មវត្ថុរបស់អាជ្ញាបណ្ណឬវិញ្ញាបនប័ត្រ	តើខ្ញុំអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រនៅឯណា?	តើខ្ញុំត្រូវមានសំណុំឯកសារអ្វីខ្លះដើម្បីអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវរង់ចាំរយៈពេលប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវចំណាយប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	កម្រងឯកសារគតិយុត្តិយោង
								- ៤០០.០០០រៀល ចំពោះថ្នាំកសិកម្មលើសពី២០តោន-៥០តោន - ត្រូវយកកម្រៃមូលដ្ឋានសម្រាប់បរិមាណ៥០តោនបូកបន្ថែមកម្រៃតាមបរិមាណដូចមានចែងខាងលើ ចំពោះថ្នាំកសិកម្មលើសពីតោន៥០តោន - សម្រាប់ការស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយនូវថ្នាំកសិកម្ម និងជីកសិកម្មត្រូវបង់កម្រៃសរុបរួមតាមកម្រិតបរិមាណថ្នាំកសិកម្ម និងជីកសិកម្មដែលស្នើសុំប្រតិបត្តិការដូចមានបង្ហាញខាងលើ	
ដំណាក់កាល ៣	ការចុះបញ្ជីពន្ធដារ[1] កំណត់សម្គាល់៖ ម្ចាស់អាជីវកម្មចាំបាច់ធ្វើការចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការក្រោយពីម្ចាស់អាជីវកម្ម ចាប់ ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ។	អគ្គនាយកដ្ឋានពន្ធដារ ឬការិយាល័យពន្ធដារ ស្រុក ខណ្ឌ	អចិន្ត្រៃយ៍	និយមន័យរបស់អ្នកជាប់ពន្ធ៖ - អ្នកជាប់ពន្ធតូច គឺជា សហគ្រាសឯកកម្មសិទ្ធ ឬសហគ្រាសឯកសហកម្មសិទ្ធ ដែល៖ ក. មានផលរបរប្រចាំឆ្នាំចាប់ពី២៥០លានរៀល ប្រហែល (៦២.៥០០ដុល្លា សហរដ្ឋអាមេរិក) រហូតដល់ ៧០០ លានរៀល ប្រហែល (១៧៥.០០០ដុល្លាសហរដ្ឋអាមេរិក) ខ. មានផលរបរក្នុងរយៈពេលបីខែជាប់គ្នាណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្ត ចាប់ពី ៦០លានរៀលឡើងទៅ ប្រហែល (១៥.០០០ដុល្លាសហរដ្ឋអាមេរិក) គ. រំពឹងថាមានផលរបរក្នុងរយៈពេលបីខែជាប់គ្នាខាងមុខចាប់ពីចាប់ពី ៦០លានរៀលឡើងទៅ ប្រហែល (១៥.០០០ដុល្លា សហរដ្ឋអាមេរិក) ឃ. ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃឬស្នងថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញ និងសេវាកម្មរួមទាំងភាស៊ីលរួមដេញថ្លៃ។ - អ្នកជាប់ពន្ធមធ្យម គឺជា៖ ក. សហគ្រាសដែលមានផលរបរប្រចាំឆ្នាំចាប់ពី៧០០លានរៀល ប្រហែល (១៧៥.០០០ដុល្លាសហ	អគ្គនាយកដ្ឋានពន្ធដារ ឬការិយាល័យពន្ធដារ ស្រុក ខណ្ឌ ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិច	លោកអ្នកតម្រូវឱ្យបំពេញសំណុំឯកសារមួយចំនួនដូចខាងក្រោមសម្រាប់ដំណើរការស្នើសុំចុះបញ្ជីពន្ធដារ៖ ចំពោះអ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ (សហគ្រាសឯកបុគ្គល និងសហគ្រាសនីតិបុគ្គល) - ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាសត្រូវបានតម្រូវឱ្យមកថតរូប ស្កេនម្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសាពើពន្ធ - ក្នុងករណីចាំបាច់ អ្នកជាប់ពន្ធអាចស្នើសុំឱ្យរដ្ឋបាលសារពើពន្ធផ្តល់សេវាទៅថតរូប និងស្កេនម្រាមដៃដល់ទីតាំងសហគ្រាស ឬទីកន្លែងសមស្របណាមួយ - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ (ឧទាហរណ៍ វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មចេញដោយ ក្រសួងពាណិជ្ជកម្ម) - លក្ខន្តិកៈសម្រាប់នីតិបុគ្គល ឬ/និង - ព័ត៌មានគណីធនាគាររបស់សហគ្រាស ដូចជាលិខិតបញ្ជាក់គណនីធនាគាររបាយការណ៍ធនាគារ ឬសៀវភៅគណនីដែលចេញដោយធនាគារ - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនដែលមានសុពលភាព - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ៣ខែដែលមានទំហំ ៣៥ X ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ២សន្លឹកដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធានក្រុមប្រឹក្សាភិបាល - ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលទ្រព្យ ឬព័ត៌មានអចលទ្រព្យ - ឯកសារផ្សេងៗដែលចេញដោយអាជ្ញាធរពាក់ព័ន្ធ។ ចំពោះអ្នកជាប់ពន្ធតូច ឬបុគ្គលទាំងឡាយណាដែលមានសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានកម្រិតផលរបរប្រចាំឆ្នាំ២៥០ លានរៀល ឬមានផលរបរក្នុងរយៈពេលបីខែណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម៦០ លានរៀលត្រូវបានតម្រូវឱ្យមានភ្ជាប់ជាមួយនូវ៖	ដើម្បីទទួលបានការចុះបញ្ជីពន្ធដារ - ត្រូវការរយៈពេល ពី០១ថ្ងៃ ទៅ ០៧ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិច - ឬត្រូវការរយៈពេល ពី០៧ថ្ងៃទៅ១០ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះការចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធដោយផ្ទាល់	- កម្រៃសេវាសម្រាប់ការសុំការចុះឈ្មោះបញ្ជីពន្ធដារសម្រាប់អ្នកជាប់ពន្ធតូច គឺ ២០.០០០រៀល - កម្រៃសេវាសម្រាប់ការសុំការចុះឈ្មោះបញ្ជីពន្ធដារសម្រាប់អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ គឺ ៤០០.០០០រៀល	- ច្បាប់ស្តីពីសារពើពន្ធ - ប្រកាសលេខ៤៩៦ សហវ ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០១៦ - ប្រកាសលេខ១៨១៩ សហវ. ប្រក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៥

[1] ការផ្គត់ផ្គង់មិនជាប់អាករមានដូចតទៅ(១) សេវាប្រៃសណីយ៍សាធារណៈ (២)សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រនិងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រដែលទាក់ទិននិងការបំពេញសេវាទាំងនេះ (៣)សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ (៤) ការដឹកជញ្ជូនសាធារណៈ (៥)សេវាធានារ៉ាប់រង (៦)សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (៧)ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ ក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ (៨)សកម្មភាពមិនស្វែងរកចំណេញដើម្បីបំរើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ដំណាក់កាល	ប្រភេទអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	ស្ថាប័នមានសមត្ថកិច្ចក្នុងការចេញអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	សុពលភាព	កម្មវត្ថុរបស់អាជ្ញាបណ្ណឬវិញ្ញាបនប័ត្រ	តើខ្ញុំអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រនៅឯណា?	តើខ្ញុំត្រូវមានសំណុំឯកសារអ្វីខ្លះដើម្បីអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវរង់ចាំរយៈពេលប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវចំណាយប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	កម្រងឯកសារគតិយុត្តិយោង
				រដ្ឋអាមេរិក) រហូតដល់ ២.០០០ លានរៀល ប្រហែល (៥០០.០០០ ដុល្លាសហរដ្ឋអាមេរិក) ខ. សហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល គ. ស្ថាប័នរដ្ឋថ្នាក់ក្រោមជាតិ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល -អ្នកជាប់ពន្ធធំ គឺជា៖ ក. សហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ២.០០០ លានរៀល ប្រហែល (៥០០.០០០ដុល្លាសហរដ្ឋអាមេរិក) ខ. សាខាក្រុមហ៊ុនបរទេស គ. សហគ្រាសដែលបានចុះបញ្ជីជាគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តគ្រប់គ្រាន់ ដែលអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឃ. ស្ថាប័នរដ្ឋ បេសកកម្មទូត និងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។		- លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ (ឧទាហរណ៍ វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចេញដោយ ក្រសួងពាណិជ្ជកម្ម) បើមាន - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនដែលមានសុពលភាព - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ៣ខែដែលមានទំហំ ៣៥ X ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ២សន្លឹកដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយម្ចាស់រូបថត - ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលទ្រព្យ ឬព័ត៌មានអចលទ្រព្យ **កំណត់សម្គាល់៖**ចំពោះសំណុំឯកសារទាំងអស់ដែលជាច្បាប់ចម្លងត្រូវមានការបញ្ជាក់ពីមន្ត្រីពន្ធដារមានសមត្ថកិច្ច ឬក្រសួង ស្ថាប័នពាក់ព័ន្ធ។ ចំពោះអ្នកជាប់ពន្ធដែលមានអាស័យដ្ឋានខុសពីអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនដែលមានសុពលភាព នោះអ្នកជាប់ពន្ធចាំបាច់ត្រូវផ្តល់នូវសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។			

ដំណាក់កាល ៣	ប័ណ្ណពន្ធប៉ាតង់	អគ្គនាយកដ្ឋានពន្ធដារ ឬការិយាល័យពន្ធដារ ស្រុក ខណ្ឌ	១ឆ្នាំ		អគ្គនាយកដ្ឋានពន្ធដារ ឬការិយាល័យពន្ធដារ ស្រុក ខណ្ឌ	លោកអ្នកតម្រូវឱ្យបំពេញសំណុំឯកសារមួយចំនួនដូចខាងក្រោមសម្រាប់ដំណើរការស្នើសុំចុះបញ្ជីពន្ធដារ៖
						- បំពេញពាក្យសុំ (ពាក្យសុំទម្រង់ FORM PR 008) លោកអ្នក អាចទាញយកពីគេហទំព័រ www.tax.gov.kh
						- ប្រសិនបើអាស័យដ្ឋាននៃទីស្នាក់ការខុសពីអាស័យដ្ឋានពេលចុះបញ្ជីលោកអ្នកតម្រូវឱ្យភ្ជាប់មកជាមួយ៖
						  ○ ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម និងលិខិតប្រកាសពន្ធកាត់ទុកលើការជួលទីតាំង (ច្បាប់ចម្លង)
						  ○ លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលទ្រព្យ ឬព័ត៌មានអចលទ្រព្យ (ប្រសិនបើមាន)
						កំណត់សម្គាល់៖ចំពោះសំណុំឯកសារទាំងអស់ដែលជាច្បាប់ចម្លងត្រូវមានការបញ្ជាក់ពីមន្ត្រីពន្ធដារមានសមត្ថកិច្ច ឬក្រសួង ស្ថាប័នពាក់ព័ន្ធ។
							ដើម្បីទទួលបានប័ណ្ណពន្ធប៉ាតង់
							- ត្រូវការរយៈពេល ពី០១ថ្ងៃ ទៅ ០៧ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិច
							- ឬត្រូវការរយៈពេល ពី០៧ថ្ងៃ ទៅ១០ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះការចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធដោយផ្ទាល់
								កម្រៃសេវាសម្រាប់ការសុំប័ណ្ណពន្ធប៉ាតង់ដូចខាងក្រោម៖
								- អ្នកជាប់ពន្ធតូច ត្រូវបង់ពន្ធប៉ាតង់ចំនួន ៤០០.០០០រៀល
								- អ្នកជាប់ពន្ធមធ្យមត្រូវបង់ពន្ធប៉ាតង់ចំនួន ១.២០០.០០០ រៀល
								- អ្នកជាប់ពន្ធធំ៖
								  ○ ផលរបរលើសពី ១០.០០០.០០០.០០០ រៀល ត្រូវបង់ពន្ធប៉ាតង់ចំនួន ៥.០០០.០០០ រៀល
								  ○ ផលរបរ ១០.០០០.០០០.០០០ រៀល ឬតិចជាងត្រូវបង់ពន្ធប៉ាតង់ចំនួន ៣.០០០.០០០ រៀល
								  ○ ចំពោះអ្នកជាប់ពន្ធធំដែលមានសាខា ឃ្លាំង រោងចក្ររោងជាងសម្រាប់សកម្មភាពអាជីវកម្មតែមួយដែលស្ថិតនៅតាមរាជធានី ខេត្តផ្សេងគ្នាត្រូវបង់ពន្ធប៉ាតង់ចំនួន ៣.០០០.០០០ រៀល
									- ច្បាប់ស្តីពីសារពើពន្ធ
									- សេចក្តីណែនាំលេខ ០៣២ អពដ ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០១៦
									- ប្រកាសលេខ១៨២១ សហវ ប្រក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៥
									- ប្រកាសលេខ៩៧០ សហវ ប្រក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០១២

ដំណាក់កាល	ប្រភេទអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ	ស្ថាប័នមានសមត្ថកិច្ចក្នុងការចេញអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ	សុពលភាព	កម្មវត្ថុរបស់អាជ្ញាបណ្ណឬវិញ្ញាបនប័ត្រ	តើខ្ញុំអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រនៅឯណា?	តើខ្ញុំត្រូវមានសំណុំឯកសារអ្វីខ្លះដើម្បីអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវរង់ចាំរយៈពេលប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវចំណាយប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	កម្រងឯកសារគតិយុត្តិយោង
ដំណាក់កាល ៣	ពន្ធប្រថាប់ត្រា	អគ្គនាយកដ្ឋានពន្ធដារ ឬការិយាល័យពន្ធដារ ស្រុក ខណ្ឌ	អចិន្ត្រៃយ៍	ផ្តល់គតិយុត្តិលើឯកសារស្តីពីលិខិតស្តីពីការបង្កើតក្រុមហ៊ុន	អគ្គនាយកដ្ឋានពន្ធដារ ឬការិយាល័យពន្ធដារ ស្រុក ខណ្ឌ	លោកអ្នកត្រូវជាប់ពន្ធប្រថាប់ត្រាចំពោះលិខិតមានលក្ខណៈគតិយុត្តិដូចខាងក្រោម ៖ - លិខិតស្តីពីការបង្កើតក្រុមហ៊ុន សម្គាល់៖ អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចបង់ពន្ធប្រថាប់ត្រាឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេល០៣ខែ បន្ទាប់ពីការសម្រេចរបស់ស្ថាប័ន ឬអាជ្ញាធរមានមានសមត្ថកិច្ចដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធលិខិតទាំងនោះ។	ដើម្បីបង់ពន្ធប្រថាប់ត្រា - ត្រូវការរយៈពេល ពី០១ថ្ងៃ ទៅ ០៣ថ្ងៃ នៃថ្ងៃធ្វើការ	កម្រៃសេវាសម្រាប់ការបង់ពន្ធប្រថាប់ត្រាដូចខាងក្រោម៖ - លិខិតស្តីពីការបង្កើតក្រុមហ៊ុន ១.០០០.០០០ រៀល	- ច្បាប់ស្តីពីសារពើពន្ធ - ប្រកាសលេខ២៧៣ សហវ ប្រក ចុះថ្ងៃទី ១៧ខែមីនា ឆ្នាំ ២០១៦
ដំណាក់កាល ៤	លិខិតអនុញ្ញាត(បើកទីតាំងអាជីវកម្ម)	សាលារាជធានីភ្នំពេញ ឬសាលាខេត្តនានា	១ឆ្នាំ	- ជាព័ត៌មានដល់អាជ្ញាធរមូលដ្ឋាន - ធានាបាននូវសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក៏ដូចជាម្ចាស់អាជីវកម្ម	សាលារាជធានីភ្នំពេញ ឬសាលាខេត្តនានា (ក្នុងករណីទីតាំងអាជីវកម្មនៅតាមបណ្តាខេត្ត)	លោកអ្នកតម្រូវឱ្យបំពេញសំណុំឯកសារមួយចំនួនដូចខាងក្រោមសម្រាប់ដំណើរការស្នើសុំលិខិតអនុញ្ញាត(បើកទីតាំងអាជីវកម្ម) - ទម្រង់ពាក្យសុំលិខិតអនុញ្ញាត ជាទម្រង់លិខិតរដ្ឋបាល - រូបថតម្ចាស់អាជីវកម្ម - វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម - កិច្ចសន្យារវាងម្ចាស់អាជីវកម្ម ជាមួយនឹងអាជ្ញាធរមូលដ្ឋាន។ គោលដៅកិច្ចសន្យានោះគឺដើម្បី៖ ○ ធានាថាមិនប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ វប្បធម៌ សុខមាលភាពប្រជាជន ○ មិនមានសម្លេងរំខានប៉ះពាល់ដល់អ្នកជិតខាង ○ ហាមយកទីតាំងអាជីវកម្មដើម្បីប្រើប្រាស់ និងចែកចាយគ្រឿងញាណ ○ ហាមយកទីតាំងអាជីវកម្មជាកន្លែងជួញដូរផ្លូវភេទ និងបម្រើផ្លូវភេទ ដែលធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងតម្លៃស្ត្រី និងគ្រួសារ ○ បង្ការ និងទប់ស្កាត់ជម្លោះនានាក្នុងទីតាំងអាជីវកម្ម ○ សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការកំណត់សកម្មភាពសង្ស័យបទល្មើសផ្សេងៗ	Not found in the legal documents under the scope of this review	Not found in the legal documents under the scope of this review	Not found in the legal documents under the scope of this review
ដំណាក់កាល ៥	ចុះបញ្ជិការប្រកាសបើកសហគ្រាស (ត្រូវជូនដំណឹងដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីការចាប់ដំណើរការ និងជួលបុគ្គលិក ក្នុងកំឡុងពេល៣០ថ្ងៃ)	ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	អចិន្ត្រៃយ៍	- ធានាបានភាពស្របច្បាប់ - ធានា និងការពារផលប្រយោជន៍និងសិទ្ធិរបស់សហគ្រាស	- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(តាមរយៈប្រព័ន្ធonlineទទួលស្គាល់ដោយក្រសួងការងារ) - ក្នុងករណីសហគ្រាសមានកម្មករនិយោជិត ចាប់ពី ១នាក់ រហូតដល់ ៧នាក់ នាយកដ្ឋាន ឬមន្ទីរការងារ អាចជួយរៀបចំកម្រងសំណុំឯកសារពាក់ព័ន្ធដើម្បីចុះបញ្ជិការប្រកាសបើកសហគ្រាស	លោកអ្នកតម្រូវឱ្យបំពេញសំណុំឯកសារមួយចំនួនដូចខាងក្រោមសម្រាប់ដំណើរការស្នើសុំចុះបញ្ជិការប្រកាសបើកសហគ្រាស - ពាក្យស្នើសុំ - លក្ខន្តិកៈសហគ្រាស (ប្រសិនបើមាន) - ប័ណ្ណពន្ធប៉ាតង់ - វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងក្រសួង (ឧទាហរណ៍ ក្រសួងពាណិជ្ជកម្ម ជាដើម)	ដើម្បីទទួលបានការចុះបញ្ជិកាប្រកាសបើកសហគ្រាសត្រូវការរយៈពេល ១៥ថ្ងៃនៃថ្ងៃធ្វើការ	កម្រៃសេវាសម្រាប់ការសុំចុះបញ្ជិការប្រកាសបើកសហគ្រាសដូចខាងក្រោម៖ - និយោជិតចាប់ពី ចាប់ពី ១នាក់ រហូតដល់៧នាក់ត្រូវបង់ចំនួន ២០.០០០ រៀល - និយោជិតចាប់ពី ចាប់ពី ៨នាក់ រហូតដល់១០០នាក់ត្រូវបង់ចំនួន ៣០.០០០ រៀល - និយោជិតចាប់ពី ចាប់ពី ១០១ នាក់ រហូតដល់៥០០នាក់ត្រូវបង់ចំនួន ១០០.០០០ រៀល - និយោជិតចាប់ពី ចាប់ពី ៥០១ នាក់ ឡើងទៅត្រូវបង់ចំនួន ២០០.០០០ រៀល	- ច្បាប់ស្តីពីការងារ - ប្រកាសលេខ២២៨ កប ប្រក ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០១៤ - ប្រកាសលេខ១០០៩ សហវ ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១២

ដំណាក់កាល	ប្រភេទអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	ស្ថាប័នមានសមត្ថកិច្ចក្នុងការចេញ អាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	សុពលភាព	កម្មវត្ថុរបស់អាជ្ញាបណ្ណឬវិញ្ញាបនប័ត្រ	តើខ្ញុំអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រនៅឯណា?	តើខ្ញុំត្រូវមានសំណុំឯកសារអ្វីខ្លះដើម្បីអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវរង់ចាំរយៈពេលប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវចំណាយប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	កម្រងឯកសារគតិយុត្តិយោង
ដំណាក់កាល ៥	ចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន	ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	អចិន្ត្រៃយ៍	- ធានាបានភាពស្របច្បាប់ - ធានា និងការពារផលប្រយោជន៍និងសិទ្ធិរបស់សហគ្រាស	- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ - ក្នុងករណីសហគ្រាសមានកម្មករនិយោជិត ចាប់ពី១នាក់ រហូតដល់៧នាក់មន្ទីរការងារអាចជួយរៀបចំកម្រងសំណុំឯកសារពាក់ព័ន្ធដើម្បីចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានដោយមិនគិតកម្រៃសេវា - ក្នុងករណីសហគ្រាសមានកម្មករនិយោជិត ចាប់ពី៨នាក់ រហូតដល់១០០នាក់ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈនឹងផ្តល់ជូនតែមប្រៃសណីយ៍ តម្លៃ៣.០០០ រៀល និងជួយរៀបចំកម្រងសំណុំឯកសារពាក់ព័ន្ធមិនគិតកម្រៃសេវា - ក្នុងករណីសហគ្រាសមានកម្មករនិយោជិត ចាប់ពី១០១ឡើងទៅ នាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈនឹងផ្តល់ជូនតែមប្រៃសណីយ៍ តម្លៃ៣.០០០ រៀល និងជួយរៀបចំកម្រងសំណុំឯកសារពាក់ព័ន្ធមិនគិតកម្រៃសេវា	លោកអ្នកតម្រូវឱ្យបំពេញសំណុំឯកសារមួយចំនួនដូចខាងក្រោមសម្រាប់ដំណើរការស្នើសុំចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន - ពាក្យស្នើសុំ - លក្ខន្តិកៈសហគ្រាស (ប្រសិនបើមាន) - ប័ណ្ណពន្ធប៉ាតង់ - វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងក្រសួង (ឧទាហរណ៍ ក្រសួងពាណិជ្ជកម្ម ជាដើម)	ដើម្បីទទួលបានការចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានត្រូវការរយៈពេល ៧ថ្ងៃនៃថ្ងៃធ្វើការ	កម្រៃសេវាសម្រាប់ការសុំចុះបញ្ជិការសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានដូចខាងក្រោម៖ - និយោជិតចាប់ពី ចាប់ពី ១នាក់ រហូតដល់៧នាក់ត្រូវបង់ចំនួន ២០.០០០ រៀល - និយោជិតចាប់ពី ចាប់ពី ៨នាក់ រហូតដល់១០០នាក់ត្រូវបង់ចំនួន ៤០.០០០ រៀល - និយោជិតចាប់ពី ចាប់ពី ១០១ នាក់ រហូតដល់៥០០នាក់ត្រូវបង់ចំនួន ៨០.០០០ រៀល - និយោជិតចាប់ពី ចាប់ពី ៥០១ នាក់ ឡើងទៅត្រូវបង់ចំនួន ៨០.០០០ រៀល	- ច្បាប់ស្តីពីការងារ - ប្រកាសលេខ២២៨ កប ប្រក ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០១៤ - ប្រកាសលេខ១០០៩ សហវ ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១២
ដំណាក់កាល ៥	ចុះបញ្ជិកាសៀវភៅបើកប្រាក់	ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	អចិន្ត្រៃយ៍	- ធានាបានភាពស្របច្បាប់ - ធានា និងការពារផលប្រយោជន៍និងសិទ្ធិរបស់សហគ្រាស	- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(តាមរយៈប្រព័ន្ធonlineទទួលស្គាល់ដោយក្រសួងការងារ) - ក្នុងករណីសហគ្រាសមានកម្មករនិយោជិត ចាប់ពី១នាក់ រហូតដល់៧នាក់មន្ទីរការងារអាចជួយរៀបចំកម្រងសំណុំឯកសារពាក់ព័ន្ធដើម្បីចុះបញ្ជិកាសៀវភៅបើកប្រាក់ដោយមិនគិតកម្រៃសេវា - ក្នុងករណីសហគ្រាសមានកម្មករនិយោជិត ចាប់ពី៨នាក់ រហូតដល់១០០នាក់ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈនឹងផ្តល់ជូនតែមប្រៃសណីយ៍ តម្លៃ៣.០០០ រៀល និងជួយរៀបចំកម្រងសំណុំឯកសារពាក់ព័ន្ធមិនគិតកម្រៃសេវា - ក្នុងករណីសហគ្រាសមានកម្មករនិយោជិត ចាប់ពី១០១ឡើងទៅ នាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈនឹងផ្តល់ជូនតែម	លោកអ្នកតម្រូវឱ្យបំពេញសំណុំឯកសារមួយចំនួនដូចខាងក្រោមសម្រាប់ដំណើរការស្នើសុំចុះបញ្ជិកាសៀវភៅបើកប្រាក់ - ពាក្យស្នើសុំ - លក្ខន្តិកៈសហគ្រាស (ប្រសិនបើមាន) - ប័ណ្ណពន្ធប៉ាតង់ - វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងក្រសួង (ឧទាហរណ៍ ក្រសួងពាណិជ្ជកម្ម ជាដើម)	ដើម្បីទទួលបានការចុះបញ្ជិកាសៀវភៅបើកប្រាក់ត្រូវការរយៈពេល ៧ថ្ងៃនៃថ្ងៃធ្វើការ	កម្រៃសេវាសម្រាប់ការសុំចុះបញ្ជិការសៀវភៅបើកប្រាក់ដូចខាងក្រោម៖ - និយោជិតចាប់ពី ចាប់ពី ១នាក់ រហូតដល់៧នាក់ត្រូវបង់ចំនួន ៤០.០០០ រៀល - និយោជិតចាប់ពី ចាប់ពី ៨នាក់ រហូតដល់១០០នាក់ត្រូវបង់ចំនួន ៦០.០០០ រៀល - និយោជិតចាប់ពី ចាប់ពី ១០១ នាក់ រហូតដល់៥០០នាក់ត្រូវបង់ចំនួន ១២០.០០០ រៀល - និយោជិតចាប់ពី ចាប់ពី ៥០១ នាក់ ឡើងទៅត្រូវបង់ចំនួន ១២០.០០០ រៀល	- ច្បាប់ស្តីពីការងារ - ប្រកាសលេខ២២៨ កប ប្រក ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០១៤ - ប្រកាសលេខ១០០៩ សហវ ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១២ -

ដំណាក់កាល	ប្រភេទអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	ស្ថាប័នមានសមត្ថកិច្ចក្នុងការចេញ អាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ	សុពលភាព	កម្មវត្ថុរបស់អាជ្ញាបណ្ណឬវិញ្ញាបនប័ត្រ	តើខ្ញុំអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រនៅឯណា?	តើខ្ញុំត្រូវមានសំណុំឯកសារអ្វីខ្លះដើម្បីអាចចុះអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវរង់ចាំរយៈពេលប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬ វិញ្ញាបនប័ត្រ?	តើខ្ញុំត្រូវចំណាយប៉ុន្មានដើម្បីទទួលបានអាជ្ញាបណ្ណ ឬវិញ្ញាបនប័ត្រ?	កម្រងឯកសារគតិយុត្តិយោង
					ប្រៃសណីយ៍ តម្លៃ៣.០០០ រៀល និងជួយរៀបចំកម្រងសំណុំឯកសារពាក់ព័ន្ធមិនគិតកម្រៃសេវា				
ដំណាក់កាល ៥	ចុះទិដ្ឋាកាបទបញ្ជាផ្ទៃក្នុង	ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	អចិន្ត្រៃយ៍	- ធានាបានភាពស្របច្បាប់ - ធានា និងការពារផលប្រយោជន៍និងសិទ្ធិរបស់សហគ្រាស និងកម្មករ និយោជិត	- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(តាមរយៈប្រព័ន្ធonlineទទួលស្គាល់ដោយក្រសួងការងារ)	លោកអ្នកតម្រូវឱ្យបំពេញសំណុំឯកសារមួយចំនួនដូចខាងក្រោមសម្រាប់ដំណើរការស្នើសុំចុះទិដ្ឋាកាបទបញ្ជាផ្ទៃក្នុង - ពាក្យស្នើសុំ - លក្ខន្តិកៈសហគ្រាស (ប្រសិនបើមាន) - ប័ណ្ណពន្ធប៉ាតង់ - វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងក្រសួង (ឧទាហរណ៍ ក្រសួងពាណិជ្ជកម្ម ជាដើម)	ដើម្បីទទួលបានការចុះទិដ្ឋាកាបទបញ្ជាផ្ទៃក្នុងត្រូវការរយៈពេល ៦០ថ្ងៃនៃថ្ងៃធ្វើការ	កម្រៃសេវាសម្រាប់ការសុំចុះទិដ្ឋាកាបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម៖ - និយោជិតចាប់ពី ចាប់ពី ៨នាក់ រហូតដល់១០០នាក់ត្រូវបង់ចំនួន ៧០.០០០ រៀល - និយោជិតចាប់ពី ចាប់ពី ១០១ នាក់ រហូតដល់៥០០នាក់ត្រូវបង់ចំនួន ៣០០.០០០ រៀល - និយោជិតចាប់ពី ចាប់ពី ៥០១ នាក់ ឡើងទៅត្រូវបង់ចំនួន ៦០០.០០០ រៀល	- ច្បាប់ស្តីពីការងារ - ប្រកាសលេខ២២៨ កប ប្រក ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០១៤ - ប្រកាសលេខ១០០៩ សហវ ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១២